# HCV ➢ អក្ខរានុក្រមនៃពាក្យ

Antibodies ប្រព័ន្ធការពារមេរោគក្នុងខ្លួន (**អង្គបដិបក្ខ**)

សារជាតិប្រូតេអ៊ីនបង្កើតឡើងក្នុងខ្លួនប្រានយើង ដើម្បីវាយបនាំងតបនឹង បាក់តេរី មេរោគឬសារធាតុផ្សេងៗ។ ក្នុងករណីជំងឺរលាក ថ្លើមប្រភេទ C អង្គបដិបក្ខបានបង្កើតឡើងដើម្បីប្រឆាំងនឹងមេរោគ ហើយវាស្ថិតក្នុងខ្លួនប្រាណយ៉ាងយូរ ទោះបីជាការឆ្លងជំងឺនេះនៅតែមានវត្តមានឬគ្មាននៅក្នុងខ្លួនក៏ដោយ។

Antibody Test **ការធ្វើតេស្តអង្គបដិបក្ខ**

ជាការធ្វើតេស្តឈាម រកមើលអង្គបដិបក្ខ ជាជាងរកមើលមេរោគ។

Blood Awareness **ការប្រុងប្រយ័ត្នចំពោះឈាម** ការប្រុងប្រយ័ត្នចំពោះឈាម ដែលអាចមាននឹងកើតឡើង ឬកំពុងតែកើតឡើង នៅគ្រប់ស្ថានភាពឬទីកន្លែង។

Bulk Billing

ប្រសិន GP លោកអ្នក *bulk bills* មានន័យថាលោកអ្នកមិនត្រូវបង់ប្រាក់ទេ គឺប្រើប័ណ្ណ Medicare បង់ឱ្យ GP។ ផ្ទុយទៅវិញបើ GP មិន bulk bills ទេគឺ លោកអ្នកត្រូវ បង់ប្រាក់ទៅ GP ជាមុនសិន រួចទើបអាចទាមទារយកប្រាក់ខ្លះមកវិញពី Medicare។

Chronic **ជំងឺរ៉ាំរ៉ៃ**

ជំងឺរ៉ាំរ៉ៃ ជាជំងឺឬករណីដែលមានរយៈពេលយូរ ហើយជួនកាលធ្វើឱ្យខ្លួនប្រាណផ្លាស់ប្តូរ។

Cirrhosis

ភាពក្រិនខូចខាតជាអចិន្ត្រៃយ៍នៃថ្លើម (ក្រិនថ្លើមដែលគេហៅថា Cirrhosis)។ Cirrhosis វាប៉ះពាល់ដល់ដល់ដំណើរការរបស់ថ្លើម។ មនុស្សប្រហែល ៥-១០% នៃជំងឺរលាកថ្លើមប្រភេទ C ក្លាយទៅជា cirrhosis បើមិនបានធ្វើការព្យាបាលទេ។

Co-Infection **ការឆ្លងព្រមៗគ្នា**

ជាពាក្យសំដៅលើ ការឆ្លងព្រមគ្នានៃមេរោគពីរឬច្រើន ។ ពាក្យ hepatitis co-Infection  នេះមានន័យថា ភាពឆ្លងមេរោគរលាកថ្លើមប្រភេទ C និងមេរោគក្នុងឈាមដទៃទៀត ដូចជា HIV និង/ឬមេរោគរលាកថ្លើមប្រភេទ  B ជាដើម ។

Combination Therapy **វិធីព្យាបាលរួមគ្នា**

ជាវិធី ដែលប្រើថ្នាំពីរមុខ ឬច្រើនមុខ ក្នុងពេលតែមួយដើម្បីធ្វើការ ព្យាបាល ជំងឺរលាកថ្លើមប្រភេទ C ។ ពាក្យនេះ បច្ចុប្បន្នគេ សំដៅទៅលើការប្រើវិធីរួមផ្សំរវាងថ្នាំ  interferon និងថ្នាំ ribavirin ។

Complementary Therapies **វិធីព្យាបាលរួមផ្សំ**

ជាវិធីព្យាបាលបន្ថែមដែលមិនមែនជាចំណែកនៃការព្យាបាលតាមរបៀបថ្នាំពេទ្យ ។ ចំពោះជំងឺរលាកថ្លើមប្រភេទ Cវិធីព្យាបាលបន្ថែមនេះ តែងប្រើដើម្បីបន្ថយ ការធ្វើ ទុក្ខនៃ antiviral ។

Condom**ស្រោមអនាម័យ**

ជាស្រោមកៅស៊ូស្តើង សំរាប់ពាក់លើលិង្គបុរស ដើម្បីការពារដៃគូរកុំអោយមានផ្ទៃពោះ ឬការពារការចំលង ជំងឺកាមរោគផ្សេងៗ ។

Confidentiality**ការរក្សាភាពសំងាត់**

គឺជាបទបញ្ជា សំរាប់ហាមបុគ្គលិកសុខភាព វេជ្ជបណ្ឌិត និងអ្នកបកប្រែ ពីការនិយាយនូវអ្វីដែល គេបានដឹងពីសុខភាពលោកអ្នកទៅកាន់អ្នកដទៃ ។ បុគ្គលិកអាចនិយាយបាន លុះ ត្រាតែមានការអនុញ្ញាតពីលោកអ្នក ឬករណីពិសេស ។

Counsellor**អ្នកផ្តល់ឱវាទនិងយោបល់**

ជាអ្នកជំនាញដែលចាំស្តាប់នូវ បញ្ហាផ្ទាល់ខ្លួនលោកអ្នក និង ជួយរកដំណោះស្រាយ ។ អ្នកផ្តល់ឱវាទ ក៏ត្រូវអនុវត្តច្បាប់ការរក្សាភាពសំងាត់ដែរ ។ ពួកគេធ្វើការនៅតាមគ្លីនិកសុខភាពសហគមន៍ កិច្ចបំរើសុខភាពខួរក្បាល និងគ្លីនិកផែនការគ្រួសារ ។

Diagnosis **រោគវិនិច្ឆ័យ**

គឺជាការសន្និដ្ឋានប្រភេទជំងឺរបស់វេជ្ជបណ្ឌិត ក្រោយពីបានពិនិត្យមើល រោគសញ្ញានិងប្រវត្តិជំងឺ តាមដានធ្វើតេស្ត និងពិភាក្សាជាមួយអ្នកជំងឺ ។

**Discrimination ការរើសអើង**

ការធ្វើអំពើមិនសមរម្យ ទៅលើនរណាម្នាក់ដោយសារតែគេជា ឧទាហរណ៍ ជន អន្តោប្រវេសន៍ ស្ត្រីភេទ ជនមានជំងឺរលាកថ្លើមប្រភេទ C ។ល ។ នៅប្រទេសអូស្ត្រាលី អំពើរើសអើងជាអំពើខុសច្បាប់ ។

Disease **ជំងឺ**

ការមិនស្រួលខ្លួន ការឈឺ

Fibroscan

តេស្តម៉្យាងដែលមិនឈឺ សំរាប់វាស់ឱ្យ ដឹងពីកំរិតខូចខាតនៃថ្លើមដោយប្រើ altrasound ពិសេសម្យ៉ាង ។

Genotype

ជាពាក្យប្រើដើម្បី រៀបរាប់ ទំរង់ពិសេសនៃមេរោគរលាកថ្លើមប្រភេទ C ។ Gynotype និមួយៗត្រូវការភាពស៊ាំខុសៗគ្នាដើម្បីទប់ទល់ ហើយឆ្លើយតបទៅនឹងការព្យាបាលខុសៗគ្នា ។ មេរោគរលាកថ្លើមប្រភេទ C មាន gynotypes 1,2,3 និង 4 ។

Hepatitis

ពាក្យនេះមានន័យថាការរលាកថ្លើម ។ ការរលាកថ្លើមបណ្តាលមកពី សេពសុរាហួសកំរិត ឬមេរោគផ្សេងៗ ។ ជាទូទៅ មេរោគរលាកថ្លើមដែលជួបប្រទះច្រើនជាងគេគឺ ប្រភេទ A,B និង C ។

HIV (The Human Immunodeficiency Virus) **ហេចអាយវី**

មេរោគដែលធ្វើអោយប្រព័ន្ធប្រឆាំងនឹងមេរោគក្នុងខ្លួនយើង ចុះខ្សោយ ។ មេរោគនេះ បណ្តាលអោយ ទៅជាជំងឺអេដស៍ ។

Infection **ការឆ្លងមេរោគ**

ជំងឺដែលទាក់ទងនឹងការបង្ក សរីរាង្គតូចៗ (មេរោគ) ក្នុងនិងក្រៅខ្លួនមនុស្សយើង ។ ភាពចំលងជំងឺនេះ អាចបណ្តាលអោយយើងឈឺ ។ ភាពចំឡងជំងឺអាចបណ្តាលមកពីមេរោគ វីរ៉ុស បាក់តេរី ហ្វាងគី ឬប៉ារ៉ាស៊ីត (viruses, bacteria, fungi or parasites) ។

Injecting

ការប្រើម្ជុលនិងសារាំងដែលផ្ទុកថ្នាំចាក់ក្នុងសរសៃឈាម ក្រោមស្បែក ឬក្នុងសាច់ដុំ ។

Injecting Drug User (IDU) **អ្នកចាក់គ្រឿងញៀន** ជាពាក្យសំដៅលើជនដែលប្រើគ្រឿងញៀន ដោយប្រើម្ជុលនិងសារ៉ាំងចាក់ចូលក្នុង សរសៃឈាម ឬសាច់ដុំ ។

Interferon

សារធាតុបង្កើតឡើងក្នុងខ្លួនមនុស្សយើង ដើម្បីជួយការពារមេរោគឆ្លង ។ ការប្រើថ្នាំ Interferon ដែលបានផលិតតាមរោងចក្រក្នុងកំរិតច្រើនអាចជួយបន្ថយមេរោគ

រលាកថ្លើមប្រភេទ C ក្នុងឈាម ឬបញ្ឈប់ជំងឺនេះ ។

Liver Biopsy

ជាការធ្វើតេស្ត ដោយកាត់យកថ្លើមមួយកូនដុំតូច ដើម្បីពិនិត្យមើលសុខភាពថ្លើម ។

Monitor**ការតែកត្រួតពិនិត្យ**

ការតែកត្រួតពិនិត្យដោយទៀងទាត់ ដើម្បីតាមដានទូវការវិវឌ្ឍន៍ ជំងឺរលាកថ្លើមប្រភេទ C ។

Side Effect

ការធ្វើទុក្ខនៃថ្នាំ

Social Worker **បុគ្គលិកសង្គមកិច្ច**

បុគ្គលិកជំនាញ ដែលត្រូវបានហាត់ហ្វឹកហ្វឺនពិសេស ដើម្បីជួយដោះស្រាយ ដល់អ្នកមានបញ្ហាដើម្បីរកដំណោះស្រាយសង្គម ។ បុគ្គលិកទាំងនេះក៏ប្រកាន់ ច្បាប់រក្សាភាពការសំងាត់ដែរ ។

Standard drink

កំរិតខ្នាតនៃភេសជ្ជៈដែលមានជាតិសុរាស្របច្បាប់  គឺជាភេសជ្ជៈដែលមានស្រាចមនួន ១០ ក្រាម ឧទាហរណ៍ មួយជិបនៃស្រាស ។ ភេសជ្ជៈដែលមានកំរិតខ្នាតនៃជាតិសុរាស្របច្បាប់ តែងតែមានចំនួនស្រាដូច១គ្នា ទោះជាទំហំដប ឬកែវ ឬប្រភេទស្រាខុស១គ្នាក៏ដោយ ឧទាហរណ៍ ប៊ីយែរ (beer) ស្រាក្រហម (Red Wine) ស្រាស (spirit).

Test **ការធ្វើតេស្ត**

វិធីស្វែងរកជំងឺ ដោយយកឈាម ជាតិទឹកក្នុងខ្លួន ឬសាច់ក្នុងខ្លួនយើងយកទៅពិនិត្យមើល ។

Transmission **ការចំលង**

ការចំលងជំងឺពី មនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។

Treatment **ការព្យាបាល**

ជាអំពើដែលមនុស្សម្នាក់ធ្វើដើម្បីជួយឱ្យគេមានសុខភាពល្អ ឬប្រសើឡើង ។ ការព្យាបាលអាចទាក់ទងនឹងការលេបថ្នាំ វិធីព្យាបាលបន្ថែម ឬការផ្លាស់ប្តូររបៀបរស់នៅ ។

Viral Load

ចំនួននៃមេរោគ (មេរោគរលាកថ្លើមប្រភេទ C) ដែលគេរកឃើញក្នុងឈាមមនុស្ស ប្រសិនបើមនុស្សនោះឆ្លងមេរោគរលាកថ្លើមប្រភេទ C ។

Virus មេរោគវីរុស

ជាមេរោគ (micro-organism, microbe) ដែលថ្នាំផ្សះ( antibiotc ) ធម្មតា មិនអាចព្យាបាលជាបាន ។ HIV, hepatitis A, B, C សុទ្ធតែជាមេរោគវីរុស ។